# របាយការណ៍ប្រចាំខែកុម្ភៈ ឆ្នាំ ២០១៦ របស់មន្ទីរអភិវឌ្ឍន៍ជនបទ ខេត្តឧត្តរមានជ័យ

## ១. សេចក្តីផ្តើម

ខេត្តឧត្តរមានជ័យស្ថិតនៅទិសឧត្តរនៃព្រះរាជាណាចក្រកម្ពុជា មានចម្ងាយប្រមាណ ៤៤១ គីឡូម៉ែត្រ ពីរាជធានីភ្នំពេញ មានផ្ទៃដីសរុបចំនួន ៦.៦៣១,៧២ គីឡូម៉ែត្រក្រឡា។ ខេត្តនេះមានព្រំប្រទល់ខាងកើតជាប់នឹងខេត្តព្រះវិហារ ខាងលិចជាប់នឹង ខេត្តបន្ទាយមានជ័យ ខាងត្បូងជាប់នឹងខេត្តសៀមរាប និងខាងជើងប្រវែង ២២៥ គីឡូម៉ែត្រជាប់នឹងខេត្តស៊ីសាកេត ខេត្តបុរីរ៉ាំ និងខេត្តសុរិន្ទ្រ ប្រទេសថៃ និងមានស្រុកចំនួន ០៤ និងក្រុង ១ គឺស្រុកអន្លង់វែង ស្រុកត្រពាំងប្រាសាទ ស្រុកចុងកាល់ ស្រុកបន្ទាយអំពិល និងក្រុងសំរោង។

## ២. ស្ថានភាពរបស់មន្ទីរ

### ២.១ ការងាររដ្ឋបាល និងបុគ្គលិក

មន្ទីរអភិវឌ្ឍន៍ជនបទខេត្តឧត្តរមានជ័យ ដឹកនាំដោយប្រធានមន្ទីរ ០១ រូប និងអមដោយអនុប្រធានមន្ទីរចំនួន ០២ រូប រួមមាន÷ បុគ្គលិកសរុបចំនួន ៣២ នាក់ ក្នុងនោះនៅកម្រិតរដ្ឋបាលថ្នាក់មន្ទីរមានការិយាល័យជំនាញចំនួន ០៨ និងថ្នាក់ស្រុក ០៥។

### ២.២ កិច្ចប្រជុំផ្សេងៗ និងទំនាក់ទំនងសាធារណៈ:

- ថ្ងៃទី ២៧ ខែមករា លោកអនុប្រធានមន្ទីរ ចូលរួមក្នុងសន្និបាតបូកសរុបលទ្ធផលការងារឆ្នាំ ២០១៥ និងលើកទិសដៅការងារឆ្នាំ ២០១៦ របស់សាលាខេត្តឧត្តរមានជ័យ
- ថ្ងៃទី ២៧-២៨ ខែមករា មន្ត្រីការិយាល័យសុខភាពជនបទ បានចូលរួមកិច្ចប្រជុំប្រចាំត្រីមាសទី ៤ ឆ្នាំ ២០១៥ នៃការអនុវត្តកម្មវិធី CLTS នៅខេត្តតាកែវ
- ថ្ងៃទី ២៨ ខែមករា លោកប្រធានមន្ទីរអញ្ជើញចូលរួមប្រជុំពិនិត្យលទ្ធផលការងារនៃការអនុវត្តរបស់អនុគណៈកម្មការអន្តរក្រសួង ដើម្បីត្រួតពិនិត្យ វាស់វែង និងវាយតម្លៃសម្បទានដីសេដ្ឋកិច្ច ក្រោមអធិបតីភាពឯកឧត្តម **ឧបនាយករដ្ឋមន្ត្រី ប៊ិន ឈិន** នៅសាលាខេត្តឧត្តរមានជ័យ
- ថ្ងៃទី ២៩ ខែមករា លោកអនុប្រធានមន្ទីរ ចូលរួមពិធីបើកសន្និបាតបូកសរុបការងារអប់រំយុវជន និងកីឡា ឆ្នាំសិក្សាឆ្នាំ ២០១៤-២០១៥ នៅមន្ទីរអប់រំយុវជន និងកីឡាខេត្តឧត្តរមានជ័យ
- ថ្ងៃទី ២៩ ខែមករា លោកប្រធានមន្ទីរ និងអនុប្រធានមន្ទីរ ០២ រូប ចូលរួមប្រជុំពិភាក្សាការងាររបស់មន្ទីរអង្គភាពជុំវិញខេត្ត ក្រោមអធិបតីភាព **ឯកឧត្តម ស ថាវី** អភិបាលនៃគណៈអភិបាលខេត្តឧត្តរមានជ័យ
- ថ្ងៃទី ០២ ខែកុម្ភៈ លោកអនុប្រធានមន្ទីរ ចូលរួមបើកកម្មវិធីប្រកួតកីឡាសិស្សបឋម មធ្យមសិក្សាជ្រើសរើសជើងឯក ថ្នាក់ខេត្ត នៅបហុកីឡាដ្ឋានខេត្តឧត្តរមានជ័យ
- ថ្ងៃទី ០២ ខែកុម្ភៈ មន្ត្រីការិយាល័យរដ្ឋបាល ចូលរួមប្រជុំបូកសរុបរបាយការណ៍វឌ្ឍនភាព ប្រចាំ

ឆ្នាំ ២០១៥ និងទិសដៅឆ្នាំ ២០១៦ នៃការអនុវត្តកម្មវិធីអភិវឌ្ឍន៍សេដ្ឋកិច្ចតំបន់ (Red III) ខេត្តឧត្តរមានជ័យ

- ថ្ងៃទី ០២ ខែកុម្ភៈ អនុប្រធានការិយាល័យរដ្ឋបាលចូលរួមក្នុងកិច្ចប្រជុំពិភាក្សា ស្តីពីការគ្រប់គ្រងបញ្ជីវត្តមាន នៅតាមអង្គភាពក្រោមឱវាទក្រសួងអភិវឌ្ឍន៍ជនបទ នៅទីស្តីការក្រសួងអភិវឌ្ឍន៍ជនបទ
- ថ្ងៃទី ០៤ ខែកុម្ភៈ លោកប្រធានមន្ទីរ អញ្ជើញចូលរួមក្នុងកិច្ចប្រជុំសាមញ្ញលើកទី ២១ របស់ក្រុមប្រឹក្សាខេត្តឆ្នាំទី ២ អាណត្តិទី ២ នៅសាលាខេត្តឧត្តរមានជ័យ
- ថ្ងៃទី ១០ ខែកុម្ភៈ លោកអនុប្រធានមន្ទីរចូលរួមកិច្ចប្រជុំបូកសរុបរបាយការណ៍អនុវត្តការងារប្រចាំឆ្នាំ ២០១៥ និងលើកទិសដៅបន្តឆ្នាំ ២០១៦ នៃគណៈកម្មាធិការប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស ក្រោមអធិបតីភាព **ឯកឧត្តម ស ថាវី** អភិបាល នៃគណៈអភិបាលខេត្តឧត្តរមានជ័យ នៅសាលប្រជុំសាលាខេត្ត
- ថ្ងៃទី ១០ ខែកុម្ភៈ លោកប្រធានមន្ទីរ អញ្ជើញចូលរួមវេទិកាសាធារណៈ ក្រោមអធិបតីភាព **ឯកឧត្តម ស ថាវី** អភិបាលនៃគណៈអភិបាលខេត្តឧត្តរមានជ័យ នៅភូមិគោកស្អាន ឃុំក្រសាំង ស្រុកចុងកាល់ ខេត្តឧត្តរមានជ័យ
- ថ្ងៃទី ១៩ ខែកុម្ភៈ លោកអនុប្រធានមន្ទីរ ចូលរួមជាអធិបតីក្នុងពិធីសិក្ខាសាលាបញ្ចប់គម្រោងស៊ីសោម ជំហាន ០១ និងការដាក់ដំណើរការគម្រោងស៊ីសោមជំហាន ០២ (២០១៦-២០១៩) នៅសាលាខេត្តឧត្តរមានជ័យ
- ថ្ងៃទី ១៩ ខែកុម្ភៈ មន្ត្រីទទួលបន្ទុកការងារអង្គការមិនមែនរដ្ឋាភិបាល ចូលរួមប្រជុំប្រចាំឆ្នាំ ២០១៥-២០១៦ នៅខេត្តព្រះសីហនុ
- ថ្ងៃទី ១៩ ខែកុម្ភៈ លោកប្រធានមន្ទីរ អញ្ជើញចូលរួមក្នុងពិធីចែកប័ណ្ណកម្មសិទ្ធិជូនប្រជាពលរដ្ឋចំនួន ២៣ គ្រួសារ នៅភូមិថ្មល់កែង ឃុំអន្លង់វែង ស្រុកអន្លង់វែង
- ថ្ងៃទី ២៤ ខែកុម្ភៈ មន្ត្រីការិយាល័យសុខភាពជនបទ ចូលរួមសន្និបាតសុខាភិបាលខេត្តឧត្តរមានជ័យលើកទី ១៣ និងការពិនិត្យរួមគ្នាសមិទ្ធផលសុខាភិបាលឆ្នាំ ២០១៥ និងទិសដៅឆ្នាំ ២០១៦ នៅមន្ទីរសុខាភិបាលខេត្តឧត្តរាមានជ័យ

## ៣. លទ្ធផលសម្រេចបានតាមវិស័យ

### ៣.១ ការងារផ្គត់ផ្គង់ទឹកស្អាត

សាងសាង់ស្រះសហគមន៍ចំនួន ០២ កន្លែង នៅភូមិតាមាន់សែនជ័យ ឃុំគោកមន ០១ កន្លែង និងភូមិអូររំដួល ឃុំបេង ០១ កន្លែង ស្រុកបន្ទាយអំពិល ខេត្តឧត្តរមានជ័យ។

### ៣.២ ការអភិវឌ្ឍន៍ព្រំដែនទិសខាងជើង និងខាងលិចប្រទេស

#### ៣.២.១ ការងារសាងសង់ផ្ទះ

ភូមិតាមាន់សែនជ័យ÷ បានសាងសង់ផ្ទះសរុបចំនួន ៣៨ ខ្នង រួមមាន÷

- ផ្ទះសាងសង់សម្រេចបាន ១០០% ចំនួន ១៨ ខ្នង
- ផ្ទះសាងសង់សម្រេចបាន ៩០% ចំនួន ០៥ ខ្នង
- ផ្ទះសាងសង់សម្រេចបាន ៧០% ចំនួន ០៨ ខ្នង
- ផ្ទះសាងសង់សម្រេចបាន ៤០% ចំនួន ០៥ ខ្នង
- ផ្ទះសាងសង់សម្រេចបាន ២០% ចំនួន ០២ ខ្នង

**៤. ទិសដៅការងារបន្ត**

- ចុះត្រួតពិត្យ និងសិក្សាខ្សែផ្លូវជួសជុលបន្ទាន់ និងសាងសង់ថ្មីទូទាំងខេត្ត សម្រាប់ការអនុវត្តក្នុងឆ្នាំ ២០១៦
- ចូលរួមរៀបចំកិច្ចប្រជុំប្រចាំត្រីមាស ស្តីពីកម្មវិធីទឹកស្អាត និងអនាម័យជនបទជាមួយអង្គការដៃគូរ និងស្ថាប័នពាក់ព័ន្ធ
- ចុះពិនិត្យ និងផ្ទៀងផ្ទាត់ឡើងវិញលើភូមិ ODF ចំនួន ១៤ ភូមិ
- ចុះត្រួតពិនិត្យ និងជំរុញការសាងសង់បង្គន់អនាម័យនៅតាមគ្រួសារ
- ប្រជុំជ្រើសរើសទីតាំងអណ្តូងស្នប់អាហ្វ្រីដេវ សម្រាប់សាងសង់ថ្មីចំនួន ១៧ អណ្តូង និង
- ប្រជុំជ្រើសរើសទីតាំងអណ្តូងស្នប់អាហ្វ្រីដេវ សម្រាប់ជួសជុលចំនួន ១០ អណ្តូង។